ព្រឹត្តិបត្រផ្សព្វផ្សាយកសិកម្ម AGRICULTURAL EXTENSION BULLETIN

លេខទី ០៧ ត្រីមាសទី៤ ឆ្នាំ ២០១៨ ចេញផ្សាយដោយនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម A PUBLICATION OF THE DEPARTMENT OF AGRICULTURAL EXTENSION

Facebook : នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម / Department of Agricultural Extension



# បទពិសោធន៍ជោគជ័យរបស់សហគមន៍កសិកម្ម ដំណាំម្រេចដារមេមត់

នៅភូមិដារផ្សារ ឃុំដារ ស្រុកមេមត់ ខេត្តកំពង់ចាម

ព្រឹត្តប័ត្រព័ត៌មានកសិកម្មនេះ រៀបចំឡើងក្នុងគោលបំណងចងក្រងនូវរាល់បទពិសោធន៍ជោគជ័យផ្សេងៗ ដែលជាស្នាដៃអនុវត្តផ្ទាល់របស់កសិករ ក៏ដូចជាសហគមន៍ និងស្ថាប័នពាក់ព័ន្ធនានា ដែលមានស្នាដៃឆ្នើមក្នុងការអនុវត្តការងារប្រចាំឆ្នាំ២០១៨ មកចងក្រង និងធ្វើការផ្សព្វផ្សាយជូនដល់ប្រជាជាកសិករ សហគមន៍ និងដៃគូរពាក់ព័ន្ធ ដើម្បីជាចំណេះដឹងបន្ថែមសម្រាប់ការប្រកបរបរកសិកម្ម។

ព្រឹត្តិប័ត្រព័ត៌មានកសិកម្មនេះដែរ បានលើកយកបទពិសោធន៍ជោគជ័យ របស់សហគមន៍កសិកម្មដំណាំម្រេចដារមេមត់ មានទីតាំងនៅភូមិដារផ្សារ ឃុំដារ ស្រុកមេមត់ ខេត្តកំពង់ចាម ជាសហគមន៍ឆ្នើមប្រចាំឆ្នាំ២០១៨ ដែលបានទទួលជ័យលាភី លើការងារគ្រប់គ្រង និងដំណើរការមុខរបរប្រកបដោយជោគជ័យ ក្នុងការចងក្រងសហគមន៍កសិកម្មដំណាំម្រេចដារមេមត់ មកបង្ហាញជូនដូចខាងក្រោម៖

## ១- អំពីប្រវត្តិ

សហគមន៍កសិកម្មដំណាំម្រេចដារ មេមត់ ត្រូវបានសម្របសម្រួលបង្កើតឡើងដោយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ចាម និងមានការគាំទ្រថវិកាដោយ DGRV នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១០ នៅភូមិដារផ្សារ ឃុំដារ ស្រុកមេមត់ ខេត្តកំពង់ចាម និងមានប្រជាពលរដ្ឋស្ម័គ្រចិត្តចូលរួមជាសមាជិកសរុបចំនួន១០៨នាក់ ស្រី១២នាក់។

## ២- អំពីគោលបំណង

គោលបំណងនៃការបង្កើតសហគមន៍កសិកម្មដំណាំម្រេចដារមេមត់ គឺដើម្បីប្រមូលផ្តុំកម្លាំងផលិតកម្ម និងមធ្យោបាយផលិតកម្ម ដើម្បីរួមចំណែកពង្រីកផលិតកម្មកសិកម្ម ព្រមទាំងបង្កើនអំណាច ក្នុងការចរចាតម្លៃកសិផល និងជាតំណាងរបស់សមាជិកក្នុងការអនុវត្តការងារកសិកម្មតាមកិច្ចសន្យា ជួយសម្រួលដល់ជីវភាពរបស់សមាជិកតាមរយៈការផ្តល់សេវាផ្គត់ផ្គង់ធាតុចូលកសិកម្ម មានគុណភាពខ្ពស់ ផ្តល់ប្រាក់ឥណទានកសិកម្មដែលមានការប្រាក់ទាប ទិញលក់ផលិតផលម្រេចរបស់សមាជិកក្នុងតម្លៃសមរម្យ បណ្តុះបណ្តាលបច្ចេកទេសកសិកម្មដល់សមាជិក ដើម្បីរួមចំណែកលើកកម្ពស់ស្ថានភាពសេដ្ឋកិច្ច សង្គម និងវប្បធម៌របស់កសិករជាសមាជិកសហគមន៍កសិកម្មដំណាំម្រេចដារមេមត់ មានមូលដ្ឋាននៅស្រុកមេមត់។

## ៣- ស្ថានភាពសហគមន៍កសិកម្មដំណាំម្រេចដារមេមត់

សហគមន៍កសិកម្មដំណាំម្រេចដារមេមត់ ពេលចាប់ផ្តើមដំបូង មានសមាជិកសរុបចំនួន១០៨ នាក់ក្នុងនោះសមាជិកជានារីមានចំនួន១២នាក់ សមាជិកជាក្រុមប្រឹក្សាមានចំនួន៧នាក់ ក្នុងនោះមានសមាជិកជានារីចំនួន១នាក់ មានសមាជិកជាគណៈកម្មាធិការត្រួតពិនិត្យចំនួន៣នាក់ ក្នុងនោះមាននារីចំនួន១នាក់ មានភាគហ៊ុនសរុបចំនួន១៣៥ និងមានតម្លៃក្នុងមួយហ៊ុនចំនួន ១០០,០០០រៀល មានមូលនិធិបម្រុងចំនួន៥៦៤,៦៦៤រៀល និងមានមូលនិធិបណ្តុះបណ្តាល៨៤,៦៩៩រៀល មានដើមទុនសរុបចំនួន ១៨,៥០០,០០០រៀល មុខរបររបស់សហគមន៍កសិកម្មសម្រាប់គាំទ្រសមាជិកមានចំនួន៣ ក្នុងនោះមាន ១.ឥណទាន ២.ផ្គត់ផ្គង់ធាតុចូលកសិកម្ម ៣.

ទិញលក់ម្រេច។

រហូតមកដល់ពេលបច្ចុប្បន្ននេះ សហគមន៍កសិកម្មដំណាំម្រេចដារមេមត់ មានសមាជិកសរុបចំនួន ២៩១ នាក់ មានសមាជិកជានារីសរុបចំនួន៦២នាក់ មានសមាជិកជាក្រុមប្រឹក្សាភិបាលសរុបចំនួន៧នាក់ ក្នុងនោះមាន២នាក់ជាស្ត្រី មានសមាជិកគណៈកម្មាធិការត្រួតពិនិត្យចំនួន ៣ នាក់ ក្នុងនោះស្ត្រីមានចំនួន២នាក់ មានភាគហ៊ុនសរុបចំនួន ១,៨៩០ ដែលភាគហ៊ុននីមួយៗមានតម្លៃ ៤០០,០០០រៀល មានមូលនិធិបម្រុងចំនួន ៣០,៤៤៨,៩៥០រៀល និងមានមូលនិធិបណ្តុះបណ្តាលចំនួន ៤,៥៦៧,៣៤២រៀល មានដើមទុនសរុបចំនួន ១,១៤៩,៦១៩,៨៧៩ រៀល មុខរបររបស់សហគមន៍កសិកម្មសម្រាប់គាំទ្រសមាជិកមានចំនួន៣ ក្នុងនោះមានដូចជា៖ ១.ឥណទាន ២.ផ្គត់ផ្គង់ធាតុចូលកសិកម្ម ៣.ទិញលក់ម្រេច មានអចលនទ្រព្យដូចជា ១.ដីទំហំ ៥mx៦៤m ២.ទីស្នាក់ការ ៤.៥mx២០m ៣.ឡសម្ងួតម្រេច១ខ្នង ៤.រថយន្តដឹកទិញ១គ្រឿង។












ទ្រព្យសម្បត្តិសហគមន៍កសិកម្មដំណាំម្រេច ដារមេមត់

ទ្រព្យសម្បត្តិសហគមន៍កសិកម្មដំណាំម្រេច ដារមេមត់

## ៤. រចនាសម្ព័ន្ធគ្រប់គ្រងនៃសហគមន៍កសិកម្មដំណាំម្រេចដារមេមត់

សហគមន៍កសិកម្មដំណាំម្រេចដារមេមត់ មានរចនាសម្ព័ន្ធដូចខាងក្រោម៖

មហាសន្និបាត ជាអង្គការចាត់តាំងកំពូល ក្រោមមហាសន្និបាតមាន៖ ១. ប្រធានក្រុមប្រឹក្សាភិបាលមួយរូប និងអនុប្រធាន២ រូប ក្រោមក្រុមប្រឹក្សាភិបាលមាន ហិរញ្ញឹក ចំនួន២រូប បេឡា១ រូប លេខាធិការចំនួន១ រូប និងក្រោម ហិរញ្ញឹក បេឡា និងលេខាធិការ មាននាយកប្រតិបត្តិចំនួន១រូប ២. គណៈកម្មាធិការត្រួតពិនិត្យមានសមាជិកជាប្រធាន អនុប្រធាន និងសមាជិកចំនួន៣រូប ។

## រចនាសម្ព័ន្ធគ្រប់គ្រងនៃសហគមន៍កសិកម្មដំណាំម្រេចដារមេមត់




### ៤. វិធីសាស្ត្របង្កើនសមាជិក និងយុទ្ធវិធីបង្កើនទុនសហគមន៍

ដំណាក់កាលដំបូង បានធ្វើការផ្សព្វផ្សាយពីសារៈសំខាន់ និងតួនាទីរបស់សហគមន៍កសិកម្មដល់ប្រជាពលរដ្ឋតាមរយៈការធ្វើបទបង្ហាញដល់ប្រជាពលរដ្ឋស្តីអំពីសេវាកម្ម និងសកម្មភាពនានា ដែលសហគមន៍កំពុងជួយគាំទ្រដល់សមាជិកធ្វើការអញ្ជើញប្រជាពលរដ្ឋចូលរួមអង្កេតរាល់កម្មវិធីមហាសន្និបាតប្រចាំឆ្នាំរបស់សហគមន៍ជារៀងរាល់ឆ្នាំ លើកទឹកចិត្តដល់ប្រជាពលរដ្ឋ ដែលមានបំណងសុំចូលជាសមាជិកថ្មី។ គ្រោងផែនការសកម្មភាព និងផែនការថវិកាប្រចាំឆ្នាំលើកឡើងនូវបញ្ហាប្រឈម និងតម្រូវការដើមទុនសម្រាប់ពង្រីកមុខរបរក្នុងមហាសន្និបាត ស្នើសុំអង្គមហាសន្និបាតតម្លើងតម្លៃភាគហ៊ុនជាជំហានៗ (១០០,០០០៛-៤០០,០០០៛) សមាជិកដែលសុំចូលក្រោយៗ អង្គមហាសន្និបាតស្នើសុំឱ្យជាវភាគហ៊ុនចាប់ពី៥ហ៊ុនឡើងទៅ។

### ៥. វិធីសាស្ត្រគ្រប់គ្រងដំណើរការមុខរបរប្រកបដោយជោគជ័យ

ពង្រឹងសាមគ្គីភាព និងឯកភាពផ្ទៃក្នុងជួរថ្នាក់ដឹកនាំ និងសមាជិកសហគមន៍បង្កើតគណៈម្មការជំនាញ ដើម្បីគ្រប់គ្រងនិងដំណើរការមុខរបរ ឧទាហរណ៍ គណៈកម្មការមុខរបរទីផ្សារ ឥណទាន និងគណៈកម្មការគ្រប់គ្រងផ្គត់ផ្គង់.......ធ្វើការប្រជុំត្រួតពិនិត្យ តាមដាន វាយតម្លៃលើការងារគ្រប់គ្រង់ និងដំណើរការមុខរបរជាប្រចាំ រាយការ និងធ្វើរបាយការណ៍ពីសកម្មភាពជូនអង្គមហាសន្និបាតដើម្បីពិនិត្យ តាមដាន កែលម្អ និងអនុម័ត។

### ៦. ការបែងចែកប្រាក់ចំណេញប្រចាំឆ្នាំ

សហគមន៍ អាចទទួលបានប្រាក់ចំណេញប្រចាំឆ្នាំសរុបចំនួន១៦៨,៩២០,០០០រៀល គិតជាភាគរយ១០០% បានបែងចែកទៅលើមូលនិធិបម្រុង ៣០,៤៤៨,៩៥០រៀល គិតជាភាគរយស្មើនឹង ២០% មូលនិធិបណ្តុះបណ្តាលមានចំនួន ៤,៥៦៧,៣៤២រៀល គិតជាភាគរយ៣% ប្រាក់ភាគលាភស្មើនឹង១១៧,២២៨,៤៥៨៦៦.៨៨ រៀល ប្រាក់ចំណាយរដ្ឋបាល និងកម្មវិធីមហាសន្និបាតស្មើនឹង១៦,៦៧៥,២៥០រៀល គិតជាភាគរយ១០.១២%។

### ៧. ទ្រព្យសកម្ម

សហគមន៍មានទ្រព្យសកម្មរយៈពេលខ្លី បេឡាសាច់ប្រាក់មានដូចជាមូលនិធិបម្រុង បណ្តុះបណ្តាល សង្គ្រោះបន្ទាន់ គិតពីឆ្នាំ២០១០ មកដល់ឆ្នាំ២០១៧ សហគមន៍មានសាច់ប្រាក់ចំនួន ១៥៤,៩៨៩,៨៧៩រៀល ប្រាក់ឱ្យគេខ្ចី គិតទាំងប្រាក់ឱ្យសមាជិក និងមិនមែនសមាជិកខ្ចីមិនទាន់សង ក្នុងឆ្នាំ២០១៧ មានសាច់ប្រាក់ចំនួន ៧៥៦,០០០,០០០រៀល ការប្រាក់ នៃប្រាក់សមាជិក និងមិនមែនសមាជិកជំពាក់ដែលត្រូវ

ទាសរុបសាច់ប្រាក់មានចំនួន១៦៨,៩២០,០០០រៀល ទ្រព្យសកម្មមានរយៈពេលខ្លីផ្សេងៗ មានសាច់ប្រាក់សរុបចំនួន ៥,៧៧០,០០០រៀល សរុបទ្រព្យសកម្មរយៈពេលខ្លីមានសាច់ប្រាក់ចំនួន១,០៨៥,៦៧៩,៨៧៩ រៀល។

ទ្រព្យសកម្មរយៈពេលវែងរបស់សហគមន៍ មានដីទីស្នាក់ការតម្លៃ ៤០,០០០,០០០ រៀល អគារការិយាល័យសាងសង់អស់សាច់ប្រាក់ចំនួន ១៥១,៦៦០,០០០ រៀល សម្ភារការិយាល័យ ត្រូវចំណាយអស់ទឹកប្រាក់សរុបចំនួន ៥,០០០,០០០រៀល ឡសម្ងួតម្រេចចំណាយអស់ទឹកប្រាក់ចំនួន១០,០០០,០០០រៀល រថយន្ត ១គ្រឿង ចំណាយអស់ទឹកប្រាក់ចំនួន៣២,០០០,០០០រៀល សរុបទ្រព្យសកម្មរយៈពេលវែង មានចំនួនសាច់ប្រាក់សរុប ២៣៨,៦៦០,០០០រៀល សរុបទ្រព្យសកម្មរយៈពេលវែង និងខ្លីមានចំនួនសាច់ប្រាក់ចំនួន១,៣២៤,៣៣៩,៨៧៩រៀល។

### ៨. បំណុល និងទុន

ក្នុងឆ្នាំ២០១៧ សហគមន៍មានបំណុលសរុបចំនួន ១៧៤,៧២០,០០០រៀល និងមានទុនសរុបចំនួន ១,១៤៩,៦១៩,៨៧៩រៀល ដែលទុនទាំងនោះបានមកពី ប្រាក់ភាគហ៊ុនចំនួន ៧៥៦,០០០,០០០រៀល ប្រាក់បង់ចូលជាសមាជិកភាពមានចំនួន៣០,០០០រៀល មូលនិធិបម្រុងមានសាច់ប្រាក់ចំនួន១២៦,២៣១,១៨៦រៀល មូលនិធិបណ្តុះបណ្តាលមានសាច់ប្រាក់ចំនួន១៧,០៦៤,៦៥៣ រៀល មូលនិធិស្ម័គ្រចិត្តសម្រាប់អភិវឌ្ឍន៍សហគមន៍កសិកម្ម មានសាច់ប្រាក់ចំនួន ១៩១,៦០០,០០ រៀល មូលនិធិសង្គ្រោះបន្ទាន់មានសាច់ប្រាក់ចំនួន ១១,៦៩៤,០៤០ រៀល អំណោយបង្កើនទុន(DGRV & Bayer) មានសាច់ប្រាក់ចំនួន៤៧,០០០,០០០ រៀលទុនសរុប ១,១៤៩,៦១៩,៨៧៩រៀល សរុបបំណុល និងទុនមានសាច់ប្រាក់ចំនួន ១,៣២៤,៣៣៩,៨៧៩ រៀល។

### ៨. បញ្ហាប្រឈមដែលជួបប្រទះ

សហគមន៍មានបញ្ហាប្រឈមមួយចំនួន ដូចជា តម្លៃម្រេចធ្លាក់ចុះ ខ្វះបច្ចេកទេសដាំដុះនិងថែទាំម្រេច ខ្វះឃ្លាំងស្តុកម្រេច និងឧបករណ៍កែច្នៃ វេចខ្ចប់ម្រេច ប្រាក់ចំណូលទាបបម្រែបម្រួលអាកាសធាតុ។

### ៩. ដំណោះស្រាយ

ស្វែងរកទីផ្សារ ឬ ដៃគូរបញ្ញាទិញម្រេចក្នុងស្រុក និងក្រៅស្រុក ដើម្បីទិញម្រេចដោយផ្ទាល់ពីសហគន៍ ស្នើសុំមន្ត្រីជំនាញនិងជួលអ្នកបច្ចេកទេសបើកវគ្គបណ្តុះបណ្តាលបច្ចេកទេសដាំដុះ និងថែទាំម្រេច ដល់សមាជិកស្នើសុំជំនួយពីដៃគូអភិវឌ្ឍន៍ និងលើកគម្រោងផែនការថវិកាដោយខ្លួនឯងបង្កើនមុខរបរបន្ថែមទៀត ស្នើសុំមន្ត្រីជំនាញ និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធជួយផ្តល់ បច្ចេកទេសកសិកម្មបន្សាំទៅនឹងការប្រែប្រួលអាសធាតុ៕



សកម្មភាសហគមន៍ជួបជាមួយអ្នកបញ្ញាទិញម្រេច





សកម្មភាពថ្នាក់ដឹកនាំសហគមន៍ផ្តល់បទពិសោធន៍ដល់កសិករខេត្តមណ្ឌលគិរី និងខេត្តព្រះវិហារ ដើម្បីបង្កើតសហគមន៍កសិកម្ម

**សម្រាប់ព័ត៌មានលម្អិតសូមទំនាក់ទំនងមក៖**

- មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពង់ចាម
- សហគមន៍កសិកម្មដំណាំម្រេចដារមេមត់ នៅភូមិដារផ្សារ ឃុំដារ ស្រុកមេមត់ ខេត្តកំពង់ចាម

ទំនាក់ទំនងទូរស័ព្ទលេខ៖ ០៩៧ ៣៥៦៣ ២៦៥